អង្គការសហប្រជាជាតិ A/HRC/WG.6/46/KHM/3

មហាសន្និបាត

ផ្សព្វផ្សាយ៖ ទូទៅ
ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤

ភាសាដើម៖ អង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**ក្រុមការងារពិនិត្យឡើងវិញជាសកលតាមកាលកំណត់**
**សម័យប្រជុំលើកទី ៤៦**
ថ្ងៃទី២៩ ខែមេសា ដល់ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤

# សេចក្តីសង្ខេបសេចក្តីសន្និដ្ឋានរបស់ភាគីពាក់ព័ន្ធស្តីពីកម្ពុជា* របាយការណ៍របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស**

## I. សាវតារ

១. របាយការណ៍នេះត្រូវបានរៀបចំឡើងយោងតាមសេចក្តីសម្រេចរបស់ ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៥/១ និង ១៦/២១ ដោយបានពិចារណាលើពេលវេលានៃការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ និងលទ្ធផលនៃការពិនិត្យលើកមុន[1]។ របាយការណ៍នេះជាសេចក្តីសង្ខេបរបាយការណ៍របស់ភាគីពាក់ព័ន្ធសរុបចំនួន ៣៨[2] សម្រាប់ការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ ត្រូវបានរៀបរៀងឡើងក្នុងទម្រង់សង្ខេប ដោយសារមានការកំណត់ចំនួនពាក្យ។

## II. ព័ត៌មានផ្តល់ជូនដោយភាគីពាក់ព័ន្ធ

### ក- វិសាលភាពនៃកាតព្វកិច្ចអន្តរជាតិ[3] និងកិច្ចសហប្រតិបត្តិការជាមួយយន្តការសិទ្ធិមនុស្ស

២. មូលនិធិសិទ្ធិមនុស្ស (HRF) បានអំពាវនាវឱ្យកម្ពុជា ផ្តល់សច្ចាប័នលើឧបករណ៍សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ រួមមាន ICCPR-OP1, ICCPR-OP2 និង OP-ICESCR[4]។

៣. អង្គការឃ្លាំមើលលក្ខខណ្ឌការងាររបស់ប្រទេសចិន (CLW) ផ្តល់អនុសាសន៍ឱ្យកម្ពុជាផ្តល់សច្ចាប័នលើ ICRMW[5]។

៤. សេចក្តីសន្និដ្ឋានមួយចំនួន បានផ្តល់អនុសាសន៍ឱ្យកម្ពុជាផ្តល់សច្ចាប័នលើអនុសញ្ញា

Please recycle

របស់អង្គការអន្តរជាតិខាងការងារ ស្តីពីការធ្វើចំណាកស្រុកដើម្បីការងារឆ្នាំ១៩៤៩ (លេខ ៩៧) អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារ ស្តីពីពលករទេសន្តរប្រវេសន៍ ឆ្នាំ១៩៧៥ (លេខ ១៤៣) អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារ ស្តីពីជនជាតិដើមភាគតិច និង កុលសម្ព័ន្ធ ឆ្នាំ១៩៨៩ (លេខ ១៦៩) និង អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារ ស្តីពីអំពើហិង្សា និងការបៀតបៀនឆ្នាំ២០១៩ (លេខ ១៩០)[6]។

៥. JS21 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាផ្តល់សច្ចាប័នត្រឹមឆ្នាំ២០២៦ លើអនុសញ្ញាឆ្នាំ ១៩៥៤ ស្តីពីស្ថានភាពនៃជនគ្មានរដ្ឋ និងអនុសញ្ញាឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានរដ្ឋ[7]។

៦. JS15 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធ្វើការអញ្ជើញជាអចិន្ត្រៃយ៍ ដល់អ្នកកាន់អាណត្តិនីតិវិធីពិសេសរបស់អង្គការសហប្រជាជាតិទាំងអស់[8]។

## ខ- ក្របខណ្ឌជាតិស្តីពីសិទ្ធិមនុស្ស

### ១. ក្របខណ្ឌធម្មនុញ្ញ និងលិខិតបទដ្ឋានគតិយុត្ត

៧. មជ្ឈមណ្ឌលអាស៊ី (AC) បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធានាថា ច្បាប់ដែលបានអនុម័តក្នុងអំឡុងប្រទេសក្នុងគ្រាអាសន្នត្រូវអនុលោមតាមមាត្រា ៤ នៃ ICCPR ស្តីពីព្យួរការគោរពសិទ្ធិជាបណ្តោះអាសន្ន ហើយក្រោយរយៈពេលនៃគ្រាអាសន្ន កម្ពុជាត្រូវវាយតម្លៃអំពីភាពចាំបាច់នៃច្បាប់ទាំងនោះសម្រាប់រយៈពេលយូរ និងធ្វើការពិគ្រោះយោបល់ជាសាធារណៈ ដើម្បីវាយតម្លៃផលប៉ះពាល់នៃច្បាប់ទាំងនេះ[9]។

### ២. ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន និងវិធានការគោលនយោបាយ

៨. JS23 បានបញ្ជាក់ថា អំពើពុករលួយនៅកម្ពុជា បន្តកើតមានទាំងកម្រិតតូចធំ។ របាយការណ៍នេះ ក៏បានផ្តល់អនុសាសន៍ឱ្យកម្ពុជាពង្រឹងឯករាជ្យភាព និងគណនេយ្យភាពរបស់អង្គភាពប្រឆាំងអំពើពុករលួយ និងបង្កើតរបបអ្នករាយការណ៍ ដោយចែងនូវបទប្បញ្ញត្តិផ្តល់ការការពារសមស្របដល់អ្នករាយការណ៍ ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ[10]។

៩. CLW ផ្តល់អនុសាសន៍ឱ្យកម្ពុជាបង្កើតយន្តការបណ្តឹងឯករាជ្យមួយ ដើម្បីឱ្យអាជ្ញាធរស៊ើបអង្កេតរាល់ការចោទប្រកាន់ដែលបានរាយការណ៍ និងពាក្យបណ្តឹងអំពីអំពើទារុណកម្ម និងការប្រព្រឹត្តមិនគប្បី[11]។

---

* ឯកសារបច្ចុប្បន្ន បានចេញផ្សាយដោយពុំបានធ្វើការកែសម្រួលជាផ្លូវការ។

** មានការព្រមព្រៀងក្នុងការបោះពុម្ពផ្សាយរបាយការណ៍នេះ ក្រោយកាលបរិច្ឆេទចេញផ្សាយដូចសព្វដង ដោយសារកត្តាស្ថានភាពហួសពីលទ្ធភាពគ្រប់គ្រងរបស់ភាគីដាក់របាយការណ៍។

## គ- ការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស

### 1. ការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ ដោយពិចារណាលើច្បាប់មនុស្សធម៌អន្តរជាតិជាធរមាន

*សមភាព និងការមិនរើសអើង*

១០. JS21 បានបញ្ជាក់ថា ជនជាតិភាគតិចវៀតណាមដែលរស់នៅយូរឆ្នាំ និងខ្មែរក្រោមជាច្រើននាក់ បានបន្តរស់នៅក្នុងស្ថានភាពគ្មានតម្លៃនៅក្នុងសង្គម និងប្រឈមការលំបាកក្នុងការបញ្ជាក់អំពីឋានៈស្របច្បាប់របស់ខ្លួន[12]។

*សិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខបុគ្គល និងសេរីភាពពីការធ្វើទារុណកម្ម*

១១. JS3 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធានាថា ការប្រើប្រាស់កម្លាំងនៅតាមការប្រមូលផ្តុំគួរតែធ្វើឡើងក្នុងករណីលើកលែង និងគោរពឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍ច្បាប់ ភាពប្រុងប្រយ័ត្ន ភាពចាំបាច់ ភាពសមាមាត្រ និងគណនេយ្យភាព ព្រមទាំងផ្តល់ការបណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយ និងជាប្រចាំតាមវេលាកំណត់ដល់កងកម្លាំងសន្តិសុខដែលទទួលភារកិច្ចបំពេញការងារនៅតាមទីតាំងនៃការប្រមូលផ្តុំ[13]។

១២. គណៈកម្មការអ្នកច្បាប់អន្តរជាតិ (ICJ) បានលើកឡើងថា នគរបាលអាចចាប់ខ្លួន និងឃាត់ខ្លួនជនជាប់សង្ស័យក្នុងរយៈពេលអតិបរមា ២៤ម៉ោង មុនពេលអនុញ្ញាតឱ្យពួកគេជួបមេធាវី ដែលក្នុងអំឡុងពេលនោះ នគរបាលអាចសួរចម្លើយជនសង្ស័យ។ ករណីនេះបានដកហូតសិទ្ធិមានតំណាងស្របច្បាប់ក្នុងអំឡុងពេល ២៤ម៉ោងដំបូងនៃការឃាត់ខ្លួន ដែលជាការធានាដ៏ចាំបាច់ដើម្បីបញ្ចៀសការធ្វើទារុណកម្ម និងការប្រព្រឹត្តមិនគប្បីផ្សេងទៀតនៅក្នុងពេលឃាត់ខ្លួន[14]។

១៣. JS15 បានលើកឡើងថា អ្នកការពារសិទ្ធិមនុស្សជាច្រើននាក់ត្រូវបានឃាយី ឃាត់ខ្លួន ឬកាត់ទោសក្រោមបទចោទស្រពេចស្រពិលនៃ "បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍" យោងតាមមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ។ តុលាការដែលមានចរិតនយោបាយខ្លាំង នោះមានន័យថាអ្នកដែលត្រូវបានឃុំខ្លួន និងចោទប្រកាន់តាមអំពើចិត្ត តែងតែត្រូវបានជាប់ឃុំបណ្តោះអាសន្នក្នុងរយៈពេលយូរ និងពុំមានឱកាសទទួលបានការជំនុំជម្រះដោយយុត្តិធម៌[15]។

១៤. HRF អំពាវនាវឱ្យកម្ពុជាដោះលែងអ្នកទោសមនសិការទាំងអស់ជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌ និងបញ្ចប់ការរំលោភបំពានជាប្រព័ន្ធលើកិច្ចដំណើរការនីតិវិធីត្រឹមត្រូវតាមផ្លូវច្បាប់ រួមទាំងការចាប់ខ្លួន និងការឃុំខ្លួនដោយបំពាន និងការដកហូតមេធាវី[16]។

១៥. JS22 បញ្ជាក់ថា ការប្រើប្រាស់ការឃុំខ្លួនបណ្តោះអាសន្ន នៅតែមានបរិមាណច្រើនលើសលប់។ ចំនួនអ្នកជាប់ឃុំបណ្តោះអាសន្នដ៏ច្រើនសន្ធឹកសន្ធាប់បានចូលរួមចំណែកដល់

ភាពចង្អៀតណែនក្នុងពន្ធនាគារ និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបផ្សេងទៀតនៅតាមពន្ធនាគារក្នុងប្រទេសកម្ពុជា[17]។

១៦. អង្គការលើកលែងទោសអន្តរជាតិ (AI) លើកឡើងថា យុទ្ធនាការរាជរដ្ឋាភិបាលប្រឆាំងគ្រឿងញៀន បានធ្វើឱ្យចំនួនអ្នកជាប់ឃុំនៅតាមពន្ធនាគារមានការកើនឡើងច្រើនហួសប្រមាណ។ មនុស្សរាប់ពាន់នាក់ ត្រូវបានឃុំខ្លួនតាមអំពើចិត្តជារៀងរាល់ឆ្នាំ នៅតាមមណ្ឌលឃុំឃាំងពាក់ព័ន្ធគ្រឿងញៀន ដែលខ្វះសម្ភារៈបរិក្ខារពេទ្យ និងបុគ្គលិកដែលទទួលបានការបណ្ដុះបណ្ដាលត្រឹមត្រូវ។ អ្នកជាប់ឃុំប្រឈមការរំលោភបំពានជាប្រព័ន្ធ[18]។

១៧. JS24 បានផ្ដល់អនុសាសន៍ឱ្យកម្ពុជាអនុវត្តលក្ខខណ្ឌនៃការឃុំខ្លួនឱ្យស្របតាមវិធាននៃលសាន់ ម៉ានដឺឡា ជាពិសេសទាក់ទងនឹងបទដ្ឋានគុណភាពខ្យល់ ការទទួលបានទឹកស្អាត និងការប្រើប្រាស់អគ្គិសនី[19]។

១៨. JS6 បានផ្ដល់អនុសាសន៍ឱ្យកម្ពុជា ដោះស្រាយបញ្ហាភាពចង្អៀតណែនក្នុងពន្ធនាគារតាមរយៈការលើកកម្ពស់ការប្រើប្រាស់ជម្រើសផ្សេងក្រៅពីការឃុំខ្លួនបណ្ដោះអាសន្ន[20]។

១៩. JS22 បានផ្ដល់អនុសាសន៍ឱ្យកម្ពុជាអនុញ្ញាតឱ្យមានការធ្វើអធិការកិច្ចពន្ធនាគារពីស្ថាប័នខាងក្រៅ តាមពេលវេលាកំណត់ ដោយពុំចាំបាច់ជូនដំណឹង និងដោយគ្មានការរារាំង ដោយអង្គការអន្តរជាតិឯករាជ្យ[21]។

២០. អង្គការបញ្ចប់ទណ្ឌកម្មលើរាងកាយ (ECP) បានផ្ដល់អនុសាសន៍ឱ្យកម្ពុជា ខិតខំប្រឹងប្រែងបន្ថែម ឈានទៅអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីការការពារកុមារ ដើម្បីហាមឃាត់ដាក់លាក់ជាបន្ទាន់នូវរាល់ទណ្ឌកម្មលើរូបរាងកាយកុមារ ក្នុងគ្រប់កាលៈទេសៈទាំងអស់ ទោះបីក្នុងទម្រង់ទណ្ឌកម្មស្រាលក្ដី[22]។

*រដ្ឋបាលយុត្តិធម៌ រួមទាំងនិទណ្ឌភាព និងនីតិរដ្ឋ*

២១. AI បានផ្ដល់អនុសាសន៍ឱ្យកម្ពុជាខិតខំប្រឹងប្រែងបន្ថែម ដើម្បីស៊ើបអង្កេតឱ្យបានហ្មត់ចត់ ឯករាជ្យ និងមិនលម្អៀងចំពោះការបាត់ខ្លួនដោយបង្ខំ និងកំណត់ជោគវាសនា និងទីកន្លែងរស់នៅរបស់ពួកគេ[23]។

២២. JS3 បានផ្ដល់អនុសាសន៍ឱ្យកម្ពុជាពង្រឹងយន្តការត្រួតពិនិត្យលើកងកម្លាំងនគរបាល និងមន្ត្រីយោធាបច្ចុប្បន្ន ដើម្បីកំណត់ការទទួលខុសត្រូវលើមន្ត្រី និងកងកម្លាំងក្នុងវិស័យសន្តិសុខ ដែលពាក់ព័ន្ធករណីនៃការប្រើប្រាស់កម្លាំងហួសហេតុ ប្រឆាំងនឹងការជួបប្រជុំដោយសន្តិវិធី[24]។

២៣. JS24 បានផ្ដល់អនុសាសន៍ឱ្យកម្ពុជាធ្វើការស៊ើបអង្កេត និងកាត់ទោសឱ្យបានហ្មត់ចត់ និងមិនលម្អៀង ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋមកលើតំណាងអង្គការសង្គមស៊ីវិល និងអ្នកការពារសិទ្ធិមនុស្ស ក៏ដូចជាសមាជិកគណបក្សប្រឆាំង និងអ្នកសារព័ត៌មាន[25]។

២៤. JS6 បានលើកឡើងថា ប្រព័ន្ធតុលាការត្រូវបានប្រើប្រាស់ជាប្រចាំដើម្បីគាបសង្កត់គណបក្សប្រឆាំង ឬឃុំខ្លួនសកម្មជន សមាជិកសហជីព ឬពលរដ្ឋដែលបញ្ចេញមតិលើបញ្ហារសើបពាក់ព័ន្ធនឹងនយោបាយ តាមរយៈបទចោទប្រកាន់តាមអំពើចិត្ត ពីបទញុះញង់។ ប្រព័ន្ធតុលាការក៏ត្រូវបានញាំញីដោយអំពើពុករលួយផងដែរ[26]។

២៥. JS23 បានបញ្ជាក់ថា ស្ថាប័នតុលាការត្រូវបានមើលឃើញជាសាធារណៈថាជាស្ថាប័នរដ្ឋដែលពុករលួយខ្លាំងបំផុតមួយនៅកម្ពុជា ទោះបីជារដ្ឋធម្មនុញ្ញ និងច្បាប់បានចែងធានានូវឯករាជ្យភាពរបស់តុលាការក៏ដោយ[27]។

២៦. ICJ ផ្តល់អនុសាសន៍ឱ្យកម្ពុជា ផ្តល់ការធានាតាមផ្លូវច្បាប់ និងការអនុវត្ត នូវឯករាជ្យភាពពេញលេញ និងភាពមិនលម្អៀងរបស់ចៅក្រម និងព្រះរាជអាជ្ញា ជៀសវាងការរងសម្ពាធនយោបាយ និងឥទ្ធិពលមិនសមស្របគ្រប់ទម្រង់ រួមទាំងការធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងគោលបំណងលុបបំបាត់ឥទ្ធិពលស្ថាប័ននីតិប្រតិបត្តិលើការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃប្រព័ន្ធតុលាការ[28]។

២៧. ICJ បានបញ្ជាក់ថា មានការរាយការណ៍អំពីការរំលោភបំពានជាច្រើនករណីលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ រួមទាំងសិទ្ធិចូលរួមសវនាការសាធារណៈ សិទ្ធិការពារខ្លួន សិទ្ធិទទួលបានសមភាពនៃភាគីក្នុងរឿងក្តី សច្ចធារណ៍និរទោស និងសិទ្ធិទទួលបានសេចក្តីសម្រេចតុលាការជាសាធារណៈ និងសម្អាងហេតុសមស្រប ជាពិសេសក្នុងករណីពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្ស និងអ្នកដែលគេមើលឃើញថាមាននិន្នាការនយោបាយប្រឆាំង[29]។

២៨. JS6 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធ្វើវិសោធនកម្មមាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីធានាថា គ្រប់បុគ្គលទាំងអស់មានសិទ្ធិទទួលបានមេធាវី រួមទាំង ក្នុងសំណុំរឿងបទមជ្ឈិម[30]។

២៩. JS18 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាចាត់វិធានការបញ្ចប់ការឃុំខ្លួនអ្នកកាសែតតាមអំពើចិត្ត និងរយៈពេលយូរ ធានាការគោរពសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងអនុញ្ញាតឱ្យអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស មានសិទ្ធិមានមេធាវីតំណាង នៅគ្រប់ដំណាក់កាលនៃការឃុំខ្លួន និងការកាត់ក្តី[31]។

៣០. JS6 ផ្តល់អនុសាសន៍ឱ្យកម្ពុជាបន្តអភិវឌ្ឍ និងពង្រឹងដំណើរការឈានទៅលុបបំបាត់ការប្រើប្រាស់ការឃុំខ្លួនបណ្តោះអាសន្នច្រើនលើសលប់ លើកុមារទំនាស់នឹងច្បាប់ ដើម្បីអនុវត្តស្របតាមបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិកុមារ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន[32]។

៣១. JS6 ផ្តល់អនុសាសន៍ឱ្យកម្ពុជាចាត់វិធានការចាំបាច់ដើម្បីការពារឯកជនភាពកុមារដែលមានទំនាស់នឹងច្បាប់ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីលើរឿងក្តីព្រហ្មទណ្ឌ[33]។

*សេរីភាពជាមូលដ្ឋាន និងសិទ្ធិចូលរួមក្នុងជីវភាពនយោបាយ និងសាធារណៈ*

៣២. JS17 បានបញ្ជាក់ថា សេរីភាពនៃការបញ្ចេញមតិនៅកម្ពុជាបានធ្លាក់ចុះចាប់តាំងពីការពិនិត្យឡើងវិញជាសកលតាមកាលកំណត់លើកចុងក្រោយ។ បញ្ហាធំៗដែលគួរឱ្យព្រួយបារម្ភរួមមានការកាត់ទោសព្រហ្មទណ្ឌ និងការចាប់ខ្លួនអ្នកប្រើសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ការវាយប្រហារលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ រួមទាំងការបិទប្រព័ន្ធផ្សព្វផ្សាយ និងសកម្មភាពបំភិតបំភ័យ និងការយាយីប្រឆាំងនឹងប្រព័ន្ធផ្សព្វផ្សាយ[34]។

៣៣. ICJ បានបញ្ជាក់ថា កម្ពុជាបានបន្តប្រើប្រាស់ច្បាប់ដែលមិនអនុលោមតាមក្របខណ្ឌសិទ្ធិមនុស្ស ដើម្បីកាត់ទោសអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងអ្នកមាននិន្នាការនយោបាយប្រឆាំង ពីបទឧក្រិដ្ឋប្រតិដ្ឋ ជាញឹកញាប់ គឺជាលទ្ធផលនៃកិច្ចដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌដែលតាមរបាយការណ៍បង្ហាញថា មានការរំលោភបំពានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[35]។

៣៤. អង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW) បានបញ្ជាក់ថា កម្ពុជាប្រើប្រាស់ការគំរាមកំហែងអំពើហិង្សា និងយកច្បាប់មកគាបសង្កត់មេដឹកនាំនៅតាមសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងសកម្មជន ដែលព្យាយាមលាតត្រដាងការរំលោភសិទ្ធិមនុស្ស អំពើពុករលួយ និងការបំពានអំណាចរបស់រដ្ឋាភិបាល[36]។

៣៥. JS12 បានលើកឡើងថា អ្នកការពារសិទ្ធិមនុស្សភាគច្រើននៅកម្ពុជា តែងតែទទួលរងនូវការយាយីតាមផ្លូវតុលាការ រួមមានការកោះហៅ ការសាកសួរ ការចោទប្រកាន់ព្រហ្មទណ្ឌ ការចាប់ខ្លួន ការឃុំខ្លួន និងការកាត់ទោស។ បទល្មើសព្រហ្មទណ្ឌ ដូចជា ការញុះញង់ ការរួមគំនិតក្បត់ និងការប្រមាថចំពោះអង្គព្រះមហាក្សត្រ ត្រូវបានប្រើជាទូទៅដើម្បីដៅមុខសញ្ញាលើអ្នកការពារសិទ្ធិមនុស្ស[37]។

៣៦. JS9 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាបញ្ឈប់ការយាយីតាមផ្លូវតុលាការ រួមទាំងការឃុំខ្លួនដោយបំពានលើអ្នកការពារសិទ្ធិមនុស្ស ជាពិសេសសកម្មជនបរិស្ថាន[38]។

៣៧. JS17 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាបញ្ចប់និទណ្ឌភាព ដោយត្រូវធ្វើការស៊ើបអង្កេត កាត់ទោស និងដោះស្រាយជាបន្ទាន់នូវករណីអំពើហិង្សាលើអ្នកកាសែត អ្នកការពារសិទ្ធិមនុស្ស អ្នកធ្វើយុទ្ធនាការនយោបាយ និងអ្នកផ្សេងទៀតដែលត្រូវបានវាយប្រហារចំពោះការអនុវត្តសិទ្ធិសេរីភាពបញ្ចេញមតិ[39]។

៣៨. JS12 បានផ្តល់អនុសាសន៍ឱ្យម្ពុជាធានាបើកចំហសេរីភាពពលរដ្ឋ ដោយអនុញ្ញាតឱ្យអ្នកការពារសិទ្ធិមនុស្ស មេដឹកនាំគណបក្សប្រឆាំង និងអ្នកសារព័ត៌មានអាចធ្វើសកម្មភាពដោយគ្មានការរារាំង គ្មានការភ័យខ្លាច ឬការយាយី ឬការសងសឹក[40]។

៣៩. JS15 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធ្វើការស៊ើបអង្កេតដោយមិនលម្អៀង ហ្មត់ចត់ និងមានប្រសិទ្ធភាពលើគ្រប់ករណីនៃការបាត់ខ្លួនដោយបង្ខំ ការវាយប្រហារ ការយាយី និងការ

បំភិតបំភ័យដល់សមាជិកសង្គមស៊ីវិល អ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន និងនាំជនល្មើសនៃបទល្មើសទាំងនោះមកកាត់ទោស[41]។

៤០. JS3 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាលុបចោល ឬវិសោធនកម្មមាត្រាក្នុងក្រមព្រហ្មទណ្ឌ ដូចជា បទបរិហារកេរ្តិ៍ បទគំរាមកំហែងថានឹងធ្វើឱ្យខូចខាត បទប្រឆាំងនឹងអ្នករាជការសាធារណៈ និងបទញុះញង់ ដើម្បីឱ្យស្របតាមមាត្រា ១៩នៃ ICCPR សំដៅជៀសវាងការប្រើប្រាស់មាត្រាទាំងនេះយកមករឹតត្បិតតាមអំពើចិត្តនូវសិទ្ធិសេរីភាពជាមូលដ្ឋាន[42]។

៤១. JS12 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាលុបចោលបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌដែលអាចប្រើប្រាស់ដើម្បីរឹតត្បិតសិទ្ធិសេរីភាពនៃការបញ្ចេញមតិ រួមទាំងបទល្មើសព្រហ្មទណ្ឌដូចជា បទប្រមាថចំពោះអង្គព្រះមហាក្សត្រ បទញុះញង់ បទបរិហារកេរ្តិ៍ជាសាធារណៈ និងបទជេរប្រមាថជាសាធារណៈ[43]។

៤២. បណ្តាញអាស៊ីសម្រាប់ការបោះឆ្នោតដោយសេរី (ANFREL) លើកឡើងថាសេរីភាពប្រព័ន្ធផ្សព្វផ្សាយ និងសិទ្ធិទទួលបានព័ត៌មាននៅកម្ពុជាធ្លាក់ចុះគួរឱ្យកត់សម្គាល់។ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ប្រឈមនឹងការរឹតបន្តឹង ហើយអ្នកសារព័ត៌មានបានរងការយាយី ខណៈស្ថាប័នប្រព័ន្ធផ្សព្វផ្សាយដែលគ្រប់គ្រងដោយរដ្ឋ បានគ្របដណ្តប់ទិដ្ឋភាពព័ត៌មានក្នុងប្រទេស[44]។

៤៣. JS9 បានបញ្ជាក់ថា អ្នកសារព័ត៌មាន និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយបន្តរងការយាយីទាំងតាមផ្លូវតុលាការ និងក្រៅប្រព័ន្ធតុលាការ រួមទាំងតាមរយៈការវាយប្រហារដោយហិង្សា ការដាក់ពន្ធនាគារ វិធានការផ្លូវច្បាប់ ការរើសអើង និងការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណិតជាដើម[45]។

៤៤. ANFREL បានបញ្ជាក់ថា ការដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយបានកើតឡើងជាញឹកញាប់ តាមរយៈការចោទប្រកាន់អំពីការផ្សព្វផ្សាយព័ត៌មានមិនពិត និងញុះញង់ឱ្យមានភាពវឹកវរក្នុងសង្គម[46]។

៤៥. HRW បញ្ជាក់ថា កម្ពុជាបានគំរាមកំហែង និងបិទប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ខណៈមេដឹកនាំគណបក្សនយោបាយ និងអ្នកគាំទ្រ សកម្មជនសង្គមស៊ីវិល និងអ្នកសារព័ត៌មានមួយចំនួន បានភៀសខ្លួនចេញពីប្រទេស ឬ បន្តនិរទេសខ្លួនដោយសារភ័យខ្លាចការចាប់ខ្លួនតាមអំពើចិត្ត[47]។

៤៦. JS12 បានបញ្ជាក់ថា បន្ទាប់ពីការបិទវិទ្យុសំឡេងប្រជាធិបតេយ្យ និងការសម្រេចចិត្តជាបន្តបន្ទាប់ក្នុងការបិទខ្ទប់គេហទំព័រនេះ គេហទំព័រផ្សេងទៀតត្រូវបានដកហូតអាជ្ញាប័ណ្ណ ហើយបុគ្គលិកស្ថាប័នទាំងនេះត្រូវបានចាប់ខ្លួនពីបទផ្សាយព័ត៌មានក្លែងក្លាយ ឬបង្ខូចកេរ្តិ៍ឈ្មោះរដ្ឋាភិបាល[48]។

៤៧. HRW បានផ្តល់អនុសាសន៍ឱ្យកម្ពុជាបញ្ឈប់ការជៀតជ្រែកតាមអំពើចិត្ត ការទប់ស្កាត់

និងការឃ្លាំមើលប្រព័ន្ធផ្សព្វផ្សាយទាំងនៅលើប្រព័ន្ធអ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងការប្រើច្បាប់គាបសង្កត់ ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ[49]។

៤៨. JS9 ផ្តល់អនុសាសន៍ឱ្យកម្ពុជាផ្តល់អាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយជូនស្ថាប័នព័ត៌មានឯករាជ្យ ឡើងវិញ រួមទាំងវិទ្យុសំឡេងប្រជាធិបតេយ្យ[50]។

៤៩. HRW បានផ្តល់អនុសាសន៍ឱ្យកម្ពុជាបញ្ឈប់ការបំភិតបំភ័យ ការឃ្លាំមើល និងការបៀតបៀនស្ថាប័នសារព័ត៌មានឯករាជ្យ អ្នកសារព័ត៌មាន និងអ្នករិះគន់រដ្ឋាភិបាល ហើយស៊ើបអង្កេត និងកាត់ទោសឱ្យបានត្រឹមត្រូវលើអ្នកទទួលខុសត្រូវចំពោះការវាយប្រហារប្រឆាំងបុគ្គលទាំងនោះ[51]។

៥០. JS12 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាបង្កើតអាជ្ញាធរផ្សព្វផ្សាយឯករាជ្យ ដោយកំណត់វិធានឱ្យបានច្បាស់លាស់ស្តីពីការបែងចែក និងការដកហូតអាជ្ញាប័ណ្ណផ្សព្វផ្សាយ ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ[52]។

៥១. JS4 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាបង្កើតរបបការពារអ្នករាយការណ៍ ពោលគឺ ត្រូវអនុម័តច្បាប់ស្តីពីការការពារអ្នករាយការណ៍[53]។

៥២. JS15 ផ្តល់អនុសាសន៍ឱ្យកម្ពុជាពិនិត្យឡើងវិញនូវច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីលុបចោលការរឹតបន្តឹងហួសហេតុលើសេរីភាពក្នុងការបង្កើតសមាគម និងដើម្បីឱ្យច្បាប់ស្របតាមមាត្រា ២១ និងមាត្រា ២២ នៃ ICCPR[54]។

៥៣. JS15 បានបញ្ជាក់ថា សង្គមស៊ីវិលបានចងក្រងឯកសារអំពីការបដិសេធតាមអំពើចិត្តចំពោះសំណើសុំរៀបចំបាតុកម្មដោយសន្តិវិធី និងការចាប់ខ្លួនអ្នករៀបចំដោយផ្អែកលើបទប្បញ្ញត្តិច្បាប់ស្រពេចស្រពិល ដូចចែងក្នុងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។ អាជ្ញាធរក៏បានប្រើកម្លាំងហួសហេតុ និងមិនសមាមាត្រ ដើម្បីបំបែកបាតុកម្មដោយសន្តិវិធី ដែលនាំទៅដល់ការចាប់ខ្លួន និងឃុំខ្លួនអ្នកតវ៉ាជាច្រើនករណី រួមទាំងអ្នកការពារសិទ្ធិមនុស្ស សកម្មជនបរិស្ថាន មេដឹកនាំគណបក្សប្រឆាំង និងសហជីព[55]។

៥៤. JS1 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាដើម្បីធានាថារាល់ការរឹតត្បិត និងការហាមឃាត់ការតវ៉ា ការជួបប្រជុំគ្នា និងបាតុកម្ម ត្រូវតែធ្វើឡើងក្នុងករណីចាំបាច់បំផុត ឱ្យស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ[56]។

៥៥. JS15 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធ្វើវិសោធនកម្មច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ដើម្បីធានាសិទ្ធិសេរីភាពពេញលេញក្នុងការជួបជុំដោយសន្តិវិធី ដូចបានកំណត់ក្នុងច្បាប់ និងបទដ្ឋានអន្តរជាតិ[57]។

៥៦. JS9 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាលើកកម្ពស់បរិយាកាសសុវត្ថិភាព និងផ្តល់លទ្ធភាពដល់បុគ្គល និងក្រុមនានា អនុវត្តសិទ្ធិសេរីភាពក្នុងការជួបជុំដោយសន្តិវិធី និងជៀសវាងការ

ប្រើកម្លាំងហួសហេតុប្រឆាំងអ្នកតវ៉ា រួមទាំងក្នុងបរិបទនៃកូដកម្មដែលសហជីពទទ្រង់សិទ្ធិការងារកំពុងបន្តធ្វើ[58]។

៥៧. HRW បានបញ្ជាក់ថា តាមការជំរុញរបស់រដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានរារាំងគណបក្សប្រឆាំងដ៏ធំមួយ គឺគណបក្សភ្លើងទៀន មិនឱ្យចូលរួមការបោះឆ្នោតកាលពីខែកក្កដា ឆ្នាំ ២០២៣ ធ្វើឱ្យការបោះឆ្នោតគ្មានន័យ[59]។

៥៨. JS17 បាននិយាយថា បទក្បត់ជាតិត្រូវបានប្រើជាទូទៅប្រឆាំងគូប្រជែងនយោបាយ រួមទាំងការកាត់ក្តីទ្រង់ទ្រាយធំលើបុគ្គលជាប់ទាក់ទងជាមួយ គណបក្សប្រឆាំង នៅចន្លោះឆ្នាំ ២០២០ ដល់ ឆ្នាំ២០២២ ដែលបុគ្គលជាច្រើនត្រូវបានកាត់ទោសពីបទក្បត់ជាតិ និងការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ[60]។

៥៩. ANFREL បានអំពាវនាវឱ្យកម្ពុជាបញ្ឈប់ការបង្ក្រាបសំឡេងគណបក្សប្រឆាំង និងចាត់វិធានការចាំបាច់ ដើម្បីធានាឱ្យមានការបោះឆ្នោតពិតប្រាកដមួយ ដោយមានការចូលរួមពីគណបក្សជាច្រើន[61]។

៦០. អង្គការ HRW បានផ្តល់អនុសាសន៍ឱ្យកម្ពុជាបញ្ឈប់ការឃាយឃាំងដោយសារហេតុផលនយោបាយ និងការកាត់ទោសសមាជិក និងអ្នកគាំទ្រគណបក្សប្រឆាំង រួមទាំងបុគ្គលមកពីគណបក្សសង្គ្រោះជាតិ និងគណបក្សភ្លើងទៀន[62]។

៦១. អង្គការ HRW បានផ្តល់អនុសាសន៍ឱ្យកម្ពុជាដោះលែងសកម្មជននយោបាយ និងសកម្មជនសង្គមស៊ីវិលទាំងអស់ជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌ ដែលពួកគេកំពុងជាប់ពន្ធនាគារ ដោយគ្រាន់តែបានអនុវត្តសិទ្ធិមនុស្សរបស់ពួកគេដោយសន្តិវិធី[63]។

*សិទ្ធិឯកជនភាព*

៦២. JS17 បានលើកឡើងថា ការត្រួតពិនិត្យមាតិកាអ៊ីនធឺណិត និងការបង្ហោះខ្លឹមសារតាមប្រព័ន្ធផ្សព្វផ្សាយសង្គម អមដោយការបិទខ្ទប់គេហទំព័រ និងការចាត់វិធានការផ្លូវច្បាប់ចំពោះខ្លឹមសារដែលអាជ្ញាធរមិនពេញចិត្ត បានកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ[64]។

៦៣. ICJ បានបញ្ជាក់ថា អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ តម្រូវឱ្យចរាចរអ៊ីនធឺណិតទាំងអស់ត្រូវឆ្លងកាត់តាមរយៈស្ថាប័ននិយតកម្ម ដែលទទួលបន្ទុកត្រួតពិនិត្យសកម្មភាពអនឡាញ មុនពេលផ្សាយបន្តដល់អ្នកប្រើប្រាស់។ អនុក្រឹត្យនេះ បង្កហានិភ័យដល់ការអនុវត្តសិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងភាពឯកជន ហើយចែងបទប្បញ្ញត្តិផ្តល់សិទ្ធិអំណាចទូលំទូលាយលើប្រតិបត្តិករចាត់តាំងដោយរដ្ឋដើម្បីបិទខ្ទប់ ឬ ផ្តាច់ការភ្ជាប់អ៊ីនធឺណិត រក្សាទិន្នន័យចរាចរណ៍ និងផ្តល់ព័ត៌មាន ស្តីពីបណ្តាញដែលអាជ្ញាធរស្នើសុំ និងដាក់ពិន័យហួសហេតុដល់ប្រតិបត្តិករទូរគមនាគមន៍ដែលមិនបានអនុលោមតាមច្បាប់[65]។

៦៤. JS12 បានបញ្ជាក់ថា កម្ពុជាខ្វះច្បាប់រឹងមាំស្តីពីការការពារទិន្នន័យ ដែលរឹតត្បិតជាក់លាក់មិនឱ្យរដ្ឋមានលទ្ធភាពចូលទៅកាន់ទិន្នន័យឯកជន[66]។

៦៥. JS17 បានផ្តល់អនុសាសន៍ឱ្យកម្ពុជា ដាក់កំហិតឱ្យជាក់លាក់លើអំណាចអាជ្ញាធរ ក្នុងការចូលរួមឃ្លាំមើល និងបិទខ្ទប់គេហទំព័រអ៊ីនធឺណែតដោយគ្មានដីកាតុលាការ ហើយកែប្រែច្បាប់ស្តីពីទូរគមនាគមន៍ឱ្យស្របតាមបទដ្ឋានអន្តរជាតិ[67]។

៦៦. HRF បានអំពាវនាវឱ្យកម្ពុជាលុបចោលអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ[68]។

៦៧. JS4 បានជំរុញឱ្យកម្ពុជាអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានស្របតាមបទដ្ឋានអន្តរជាតិ និងបង្កើតប្រព័ន្ធត្រួតពិនិត្យព័ត៌មាន[69]។

*ការហាមឃាត់ទាសភាពគ្រប់ទម្រង់ រួមទាំងការជួញដូរមនុស្ស*

៦៨. JS13 បានបញ្ជាក់ថា ការធ្វើការងារដូចទាសភាព រួមទាំងពលកម្មដោយបង្ខំ និងការជួញដូរមនុស្សសម្រាប់គោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម ត្រូវបានរាយការណ៍ជាបន្តបន្ទាប់ ជាពិសេសនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមួយចំនួន[70]។

៦៩. AI បញ្ជាក់ថា ក្នុងអំឡុងពេលរាតត្បាតនៃជំងឺកូវីដ-១៩ ក្រុមឧក្រិដ្ឋជនបានចាប់ផ្តើមជួញដូរមនុស្សពីតាមបណ្តាប្រទេសនានាចូលមកប្រទេសកម្ពុជា ដោយបង្ខំពួកគេចូលទៅក្នុងបរិវេណមានការឃាមកាមតឹងរ៉ឹង ដើម្បីធ្វើការឆបោកតាមប្រព័ន្ធអនឡាញ និងប្រតិបត្តិការល្បែងស៊ីសង ក្រោមការគំរាមកំហែងនៃអំពើហិង្សា និងការដកហូតលិខិតឆ្លងដែន។ AI បានបញ្ជាក់ថា របាយការណ៍តាមសារព័ត៌មានស៊ើបអង្កេតមួយចំនួន ភ្ជាប់មន្ត្រីរដ្ឋាភិបាល និងក្រុមគ្រួសាររបស់ពួកគេ ថាមានជាប់ពាក់ព័ន្ធនឹងទីតាំងឆបោកទាំងនោះ។ AI បានបញ្ជាក់ថា ជនរងគ្រោះនៃអំពើជួញដូរជាច្រើននាក់ ដែលអាជ្ញាធរបានជួយយកចេញពីបរិវេណទាំងនេះ ត្រូវបានគេឃុំខ្លួននៅតាមមណ្ឌលគ្រប់គ្រងដោយរដ្ឋ អស់រយៈពេលជាច្រើនខែ ក្នុងបន្ទប់ចង្អៀតណែន តម្រូវឱ្យបង់ថ្លៃ អាហារ និងទឹកស្អាត ហើយពួកគេពុំមានលទ្ធភាពជួបនឹងមេធាវីតំណាងស្របច្បាប់នោះទេ[71]។

៧០. JS16 បានលើកឡើងថា ពលកម្មកុមារ រួមទាំងទម្រង់ធ្ងន់ធ្ងរបំផុត បានបន្តជាបញ្ហាធ្ងន់ធ្ងរ។ ពលកម្មដោយបង្ខំលើកុមារនៅបន្តកើតមានក្នុងវិស័យជាច្រើន រួមទាំងក្នុងឧស្សាហកម្មមិនមានសុវត្ថិភាព និងគ្រោះថ្នាក់ ដូចជា ឡឥដ្ឋ ចម្ការកៅស៊ូ និងកសិកម្ម រោងចក្រ និងក្នុងវិស័យក្រៅប្រព័ន្ធជាដើម[72]។

៧១. JS16 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាហាមឃាត់ ការងាររបស់កុមារនៅតាមទីតាំងគ្រោះថ្នាក់ ឬ បង្កផលប៉ះពាល់ដល់កុមារ និងបង្កើតបញ្ជីការងារគ្រោះថ្នាក់ ដែលហាមឃាត់មិនឱ្យកុមារធ្វើការ និងបង្កើនធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុ ឱ្យបានច្រើនសម្រាប់អធិការកិច្ចការងារលើគ្រប់វិស័យ សំដៅអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និងគោលនយោបាយស្តីពីពលកម្មកុមារ នាំជនល្មើសនៃការរំលោភបំពានពលកម្មកុមារមកកាត់

ទោស និងបង្កើនដាក់ទណ្ឌកម្មបានធ្ងន់ធ្ងរ។ របាយការណ៍នេះក៏ផ្តល់អនុសាសន៍ឱ្យកម្ពុជាជួយគាំទ្រដល់កុមារ ដែលធ្លាប់ឆ្លងកាត់បទពិសោធន៍នៃពលកម្មកុមារក្នុងទម្រង់ដ៏អាក្រក់បំផុត និងទម្រង់ទាសភាពសម័យទំនើប ដើម្បីអាចឱ្យពួកគេទទួលបានសិទ្ធិពេញលេញ[73]។

៧២. CLW បានផ្តល់អនុសាសន៍ឱ្យកម្ពុជាសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនឱ្យកាន់តែប្រសើរជាងមុនក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាពិសេស តាមរយៈគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស និងនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដោយធ្វើការស៊ើបអង្កេត និងកាត់ទោសជនល្មើសជាប្រព័ន្ធ និងឱ្យបានតឹងរ៉ឹង។ CLW បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធានាការពារ ផ្តល់ការជួសជុល និងសំណងជំងឺចិត្តឱ្យបានសមស្របដល់ជនរងគ្រោះ រួមទាំងការស្តារនីតិសម្បទាផងដែរ[74]។

*សិទ្ធិមានការងារធ្វើ និងលក្ខខណ្ឌការងារសមរម្យ និងអំណោយផល*

៧៣. JS26 បានបញ្ជាក់ថា ចលនាសហជីពឯករាជ្យនៅកម្ពុជា កំពុងត្រូវបានដៅមុខសញ្ញាជាក់លាក់ និងជាប្រព័ន្ធ តាមរយៈការដាក់លក្ខខណ្ឌផ្នែករដ្ឋបាល ការរារាំង និងការយាយីតាមផ្លូវតុលាការ និងចោទប្រកាន់ពីបទព្រហ្មទណ្ឌ[75]។

៧៤. HRW បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីព ដោយធ្វើការពិគ្រោះយោបល់ជាមួយកម្មករ អ្នកតស៊ូមតិខាងវិស័យការងារ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីអនុវត្តឱ្យពេញលេញស្របតាមអនុសញ្ញាអន្តរជាតិខាងការងារលេខ ៨៧ (សេរីភាពនៃការបង្កើតសមាគម) និងលេខ ៩៨ (សិទ្ធិក្នុងការរៀបចំ និងចចារជាសមូហភាព)[76]។

៧៥. HRW បានផ្តល់អនុសាសន៍ឱ្យកម្ពុជាបញ្ឈប់ការយាយី ការចាប់ខ្លួនតាមអំពើចិត្ត និងការវាយប្រហារលើសហជីព និងកម្មករ ហើយធ្វើការស៊ើបអង្កេត និងកាត់ទោសជនល្មើសនៃការវាយប្រហារបែបនេះឱ្យបានត្រឹមត្រូវ[77]។

៧៦. JS12 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាទម្លាក់ចោលរាល់បទចោទលើសកម្មជនសហជីពចំពោះការជាប់ពាក់ព័ន្ធក្នុងសកម្មភាពសហជីព និងដោះលែងមេដឹកនាំនៃសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ នៃក្រុមហ៊ុនណាហ្គាវើលដ៍ ទាំងអស់[78]។

៧៧. JS13 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាអនុវត្តប្រាក់ឈ្នួលអប្បបរមាគ្រប់វិស័យនៃទីផ្សារការងារ ហើយកម្មករទាំងអស់ទទួលបានប្រាក់ឈ្នួលអប្បបរមា ដើម្បីឱ្យពួកគេមានកម្រិតជីវភាពសមរម្យសម្រាប់ខ្លួនឯង និងគ្រួសាររបស់ខ្លួនផង[79]។

៧៨. JS13 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធានាអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ការពារសិទ្ធិការងារលើគ្រប់វិស័យ និងចំពោះគ្រប់កម្មករទាំងអស់ រួមទាំងការដោះស្រាយការអនុវត្តកិច្ចសន្យាការងាររយៈពេលខ្លី ជាមធ្យោបាយគេចវេះពីច្បាប់ស្តីពីកិច្ចគាំពារសង្គម ឬរឹតបន្តឹងសកម្មភាពសហជីពពីសំណាក់និយោជក[80]។

៧៩. JS26 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធានាកិច្ចការពារតាមផ្លូវច្បាប់ប្រឆាំងនឹងអំពើហិង្សាយេនឌ័រនៅកន្លែងធ្វើការ តាមរយៈការដាក់បញ្ចូលក្នុងច្បាប់ការងារនូវនិយមន័យស្តីពីការបៀតបៀនផ្លូវភេទ និងអំពើហិង្សាយេនឌ័រ[81]។

*សិទ្ធិទទួលបានរបបសន្តិសុខសង្គម*

៨០. JS16 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាពង្រីកការធានារ៉ាប់រងសង្គម ផ្តល់សំណាញ់សុវត្ថិភាព និងផ្តល់ការគាំទ្រផ្សេងទៀតដល់គ្រួសារដែលមានកុមារស្ថិតក្នុងស្ថានភាពងាយរងគ្រោះ និងជាពិសេសជួយដល់ឪពុកម្តាយចិញ្ចឹម និងអ្នកថែទាំសាច់ញាតិដែលប្រឈមនឹងភាពក្រីក្រ និងការកេងប្រវ័ញ្ច ដោយភ្ជាប់ពួកគេជាមួយនឹងសេវាគាំទ្រកិច្ចគាំពារសង្គម[82]។

៨១. អង្គការជនពិការកម្ពុជា (CDPO) បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធានាថា ជនមានពិការភាពទាំងអស់ រួមទាំងអ្នកធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ មានលទ្ធភាពទទួលបានមូលនិធិរបបសន្តិសុខសង្គម[83]។

*សិទ្ធិទទួលបានជីវភាពរស់នៅសមរម្យ*

៨២. JS3 បានបញ្ជាក់ថា វិវាទដីធ្លីមានការកើនឡើងយ៉ាងខ្លាំង ចំនួនមនុស្សដែលត្រូវបានបណ្តេញចេញដោយបង្ខំ ឬ បានផ្លាស់ទីលំនៅកើនឡើងជារៀងរាល់ឆ្នាំ បើទោះបីជាមានការការពារផ្លូវច្បាប់ និងការផ្តល់ប័ណ្ណកម្មសិទ្ធិក៏ដោយ[84]។

៨៣. JS22 បានបញ្ជាក់ថា ចាប់តាំងពីឆ្នាំ២០១៩ រហូតដល់បច្ចុប្បន្ន យ៉ាងហោចណាស់មាន ២២,០២១គ្រួសារ បានរងផលប៉ះពាល់ដោយសារការញាំញីនៃការទន្ទ្រានយកដី ហើយមនុស្សរាប់ម៉ឺននាក់ផ្សេងទៀត បន្តខ្វះដំណោះស្រាយលើជម្លោះអូសបន្លាយរាប់ទសវត្សរ៍។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ កម្ពុជាបានធ្វើចំណាត់ថ្នាក់ឡើងវិញនូវដីរដ្ឋជាច្រើនដើម្បីប្រគល់ឱ្យក្រុមឥស្សរជនដែលមានទំនាក់ទំនងល្អជាមួយរដ្ឋ[85]។

៨៤. JS22 បានលើកឡើងថា អំពើហិង្សាដែលប្រព្រឹត្តដោយកងកម្លាំងប្រដាប់អាវុធ ការឃុំខ្លួនតាមអំពើចិត្ត និងការកាត់ទោសព្រហ្មទណ្ឌ ត្រូវបានប្រើជាប្រចាំដើម្បីបណ្តេញចេញ និងបំបិទមាត់សហគមន៍ ដោយគ្មានសំណងគ្រប់គ្រាន់ ឬ ពុំមានការផ្តល់ទីលំនៅថ្មី[86]។

៨៥. AI បានផ្តល់អនុសាសន៍ឱ្យកម្ពុជាអនុម័តវិធានការនានាដើម្បីការពារការបណ្តេញចេញដោយខុសច្បាប់ និងប្រើប្រាស់យន្តការដោយផ្អែកលើគណនេយ្យភាព និងតម្លាភាព ក្នុងការដោះស្រាយវិវាទដីធ្លីប្រកបដោយសមធម៌ និងឆាប់រហ័ស ដូចដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានជំរុញក្នុងសេចក្តីសម្រេចចិត្តលេខ ៣៦/៣២[87]។

៨៦. JS3 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធានាថា ការបណ្តេញចេញនាពេលខាងមុខនឹងអនុលោមតាមច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធ ហើយ (១) គ្រួសារដែលត្រូវបានបណ្តេញចេញ ត្រូវទទួលសំណងសមស្របសម្រាប់ដីដែលខ្លួនធ្លាប់កាន់កាប់ ដោយផ្អែក

ទៅតាមតម្លៃទីផ្សារ និងប្តូរទីតាំងលំនៅថ្មីនៅក្នុងតំបន់ដែលផ្តល់ភាពងាយស្រួលក្នុងការទទួលបានសេវាជាមូលដ្ឋាន និងឱកាសចិញ្ចឹមជីវិត (២) ការបណ្តេញចេញត្រូវបានប្រើប្រាស់ជាមធ្យោបាយចុងក្រោយតែប៉ុណ្ណោះ និង (៣) ការបណ្តេញចេញមិនត្រូវបានអនុវត្តដោយប្រើកម្លាំងហួសហេតុ ឬ មិនសមាមាត្រនោះឡើយ[88]។

*សិទ្ធិទទួលបានសេវាសុខាភិបាល*

៨៧. JS16 បានបញ្ជាក់ថា ការទទួលបានសេវាថែទាំសុខភាពដែលមានតម្លៃសមរម្យ និងប្រកបដោយគុណភាព នៅពុំទាន់ដល់កម្រិតទទួលយកបានជាសកល ជាពិសេសសម្រាប់ប្រជាជនជិតក្រីក្រ និងក្រុមស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ដែលរស់នៅកៀកនឹងបន្ទាត់ក្រីក្រ។ ការចំណាយលើសេវាថែទាំសុខភាពបានជំរុញឱ្យគ្រួសារជាច្រើនធ្លាក់ទៅក្នុងភាពក្រីក្រ និងបង្ខំគ្រួសារឱ្យទទួលយកបន្ទុកបំណុលដែលមិនអាចគ្រប់គ្រងបាន[89]។

៨៨. JS16 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាផ្តល់អាទិភាពដាក់ចេញវិធានការកែលម្អលទ្ធភាពទទួលបានសេវាសុខភាពដោយឥតគិតថ្លៃប្រកបដោយគុណភាព ជាពិសេសនៅតំបន់ជនបទ និងសម្រាប់កុមារមានពិការភាព កុមារជនជាតិភាគតិច និងកុមារទេសន្តរប្រវេសន៍ រួមទាំងតាមរយៈការពង្រីកលទ្ធភាពទទួលបានមូលនិធិសមធម៌លើសេវាសុខាភិបាលផងដែរ[90]។

៨៩. JS8 បានបញ្ជាក់ថា កុមារកង្វះអាហារូបត្ថម្ភ រួមទាំងក្រេះក្រិន ស្គមស្គាំង ខ្វះទម្ងន់ និងកង្វះមីក្រូសារជាតិ មានអត្រាខ្ពស់នៅកម្ពុជា ទោះបីជាមានកំណើនសេដ្ឋកិច្ចជាច្រើនឆ្នាំរហូតមកដល់ពេលនេះក្តី[91]។

៩០. JS25 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធានាថា អ្នករកស៊ីផ្លូវភេទទាំងអស់អាចទទួលបានសេវាសុខាភិបាល និងចាត់វិធានការចំពោះការប្រមាថ និងការរើសអើងក្នុងការទទួលបានសេវាថែទាំសុខភាព[92]។

*សិទ្ធិទទួលបានការអប់រំ*

៩១. Broken Chalk (BC) បានលើកឡើងថា ទោះបីមានឃើញការវិវឌ្ឍក៏ដោយ ក៏កុមារនៅកម្ពុជាមិនទាន់ទទួលបានបទដ្ឋានសិក្សាសមស្របនឹងអាយុរបស់ខ្លួន។ យុវវ័យជំទង់ ៥៥% បានបោះបង់ការសិក្សា នៅពេលឈានដល់អាយុ ១៧ឆ្នាំ[93]។

៩២. JS8 បានលើកឡើងថា ការចំណាយទាក់ទងនឹងការអប់រំ ដូចជា ការធ្វើដំណើរ ឯកសណ្ឋាន ស្បែកជើង សៀវភៅ ការផ្គត់ផ្គង់ និងថ្លៃសេវាក្រៅផ្លូវការដែលទាមទារ ដោយគ្រូបង្រៀន បានបង្កើតជាបន្ទុកហិរញ្ញវត្ថុធ្ងន់បំផុតសម្រាប់គ្រួសារក្រីក្របំផុត។ គ្រួសារមួយចំនួនបានយកប្រាក់កម្ចីមករ៉ាប់រងថ្លៃសិក្សាសម្រាប់កូនៗ ឬឈប់ឱ្យកូនទៅរៀន ដើម្បីកាត់បន្ថយការចំណាយ និងដើម្បីជួយធ្វើការងារសងប្រាក់កម្ចីរបស់ខ្លួន[94]។

៩៣. BC បានបញ្ជាក់ថា មានភស្តុតាងជាច្រើនបានបង្ហាញអំពីកង្វះអនាម័យ ទឹកស្អាត និងកន្លែងលាងដៃនៅតាមសាលារៀននៅកម្ពុជា ដែលបានបង្កជាឧបសគ្គដល់កុមារមករៀន និងទទួលបានលទ្ធផលល្អក្នុងការសិក្សា ជាពិសេស ក្មេងស្រី ដែលកាន់តែប្រឈមពេលមានរដូវ

ក្នុងពេលកំពុងរៀន។ កុមារមានពិការភាព ជួបការលំបាក ជាពិសេស នៅតាមសាលារៀន ប្រសិនបើមិនមានបន្ទប់ទឹកសមស្រប ឬគ្រប់គ្រាន់សម្រាប់ពួកគេប្រើប្រាស់[95]។

៩៤. BC បានលើកឡើងថា ក្មេងស្រីទទួលរងផលប៉ះពាល់ដោយបទដ្ឋានសង្គមដែលបង្កគ្រោះថ្នាក់។ ក្រោយពីទទួលបានការអប់រំ ពួកគេអាចត្រូវបានបង្ខំឱ្យទៅធ្វើការតាមរោងចក្រ ឬស្រែចម្ការ ដើម្បីផ្តល់ប្រាក់ចំណូលឱ្យបានឆាប់រហ័សដល់គ្រួសារ[96]។

៩៥. JS16 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាលើកកម្ពស់គុណភាពអប់រំនៅគ្រប់កម្រិត ជាពិសេសនៅតំបន់ជនបទ រួមទាំងកាត់បន្ថយសមាមាត្រសិស្ស-គ្រូ សំដៅជានាការបណ្តុះបណ្តាលក្នុងកម្រិតសមរម្យសម្រាប់គ្រូបង្រៀន និងបំពាក់ហេដ្ឋារចនាសម្ព័ន្ធអប់រំ ធនធានបច្ចេកវិទ្យា និងអនាម័យគ្រប់គ្រាន់នៅតាមសាលារៀន[97]។

៩៦. JS16 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធានាផ្តល់ការអប់រំកម្រិតបឋមសិក្សា ហើយការអប់រំនេតគិតថ្លៃត្រូវបានផ្តល់ជូនសម្រាប់កុមារគ្រប់រូប យ៉ាងហោចណាស់ឱ្យបានត្រឹមថ្នាក់ទី៩ និងចាត់វិធានការសកម្ម ធានាឱ្យកុមារបានចូលសិក្សាក្នុងប្រព័ន្ធអប់រំរដ្ឋ ការចំណាយហិរញ្ញវត្ថុ រួមទាំងការរួមចំណែកដោយស្ម័គ្រចិត្ត ពុំបង្កជាឧបសគ្គសម្រាប់កុមារក្នុងការទទួលបានការអប់រំដោយស្មើភាពជាមួយមិត្តភក្តិរបស់ពួកគេ[98]។

៩៧. BC បានផ្តល់អនុសាសន៍ឱ្យកម្ពុជាផ្តោតលើការផ្តល់ការអប់រំប្រកបដោយសមធម៌ និងបរិយាប័ន្នសម្រាប់កុមារមានពិការភាព កុមារជនជាតិដើមភាគតិច និងកុមាររស់នៅតំបន់ជនបទ និងតំបន់ក្រីក្រក្នុងទីក្រុង[99]។

៩៨. CDPO បានផ្តល់អនុសាសន៍ឱ្យកម្ពុជាជួយគាំទ្រការចុះឈ្មោះកុមារមានពិការភាពនៅសាលាបឋមសិក្សា ដោយប្រើប្រាស់វិធីសាស្ត្ររួមបញ្ចូល និងប្រកបដោយបរិយាប័ន្ន[100]។

៩៩. JS21 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាផ្តល់លទ្ធភាពទទួលបានការអប់រំនៅតាមសាលារដ្ឋជាសាកល និងគ្មានការរើសអើង ចំពោះកុមារគ្រប់រូប ទោះបីពួកគេមាន ឬ ពុំមានភស្តុតាងបង្ហាញអត្តសញ្ញាណគ្រប់គ្រាន់ រួមទាំង ជនជាតិវៀតណាម ដើម្បីជំរុញសម្រេចឱ្យបានគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា[101]។

*សិទ្ធិវប្បធម៌*

១០០. JS27 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាពង្រឹងការលើកកម្ពស់ប្រពៃណីវប្បធម៌ជនជាតិដើមភាគតិច និងបង្កើតកម្មវិធីថែរក្សាការប្រតិបត្តិ និងវប្បធម៌ជនជាតិដើមភាគតិចប្រកបដោយនិរន្តរភាព[102]។

*ការអភិវឌ្ឍន៍ បរិស្ថាន និងធុរកិច្ច និងសិទ្ធិមនុស្ស*

១០១. JS3 បានបញ្ជាក់ថា សកម្មជនដីធ្លីមិនអាចអនុវត្តសកម្មភាពរបស់ខ្លួនដោយសារតែកម្ពុជាបានធ្វើការបង្ក្រាបក្នុងទ្រង់ទ្រាយធំលើសេរីភាពជាមូលដ្ឋាន កាលពី ឆ្នាំ២០១៧។ មនុស្សជាច្រើនត្រូវបានឃាត់ខ្លួន ឬ មិនដូច្នោះទេ ត្រូវបានគេដៅមុខសញ្ញា[103]។

១០២. JS9 បានបញ្ជាក់ថា កម្ពុជាបានជំរុញឱ្យមានយុទ្ធនាការឃាត់ខ្លួនតាមប្រព័ន្ធតុលាការ

ប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្សផ្នែកបរិស្ថាន ដែលបានរិះគន់ប្រឆាំងការទន្ទ្រានយកដី និងការបំផ្លាញបរិស្ថាន[104]។

១០៣. JS13 បានផ្តល់អនុសាសន៍ឱ្យកម្ពុជាធានាថា អង្គភាពអាជីវកម្មដែលកំពុងដំណើរការក្នុង ឬមានទីស្នាក់ការនៅកម្ពុជា រៀបចំកិច្ចពិគ្រោះយោបល់ជាប្រព័ន្ធ និងអនុវត្តការពិនិត្យដ៏ត្រឹមត្រូវនៃសិទ្ធិមនុស្ស រួមទាំងការវាយតម្លៃផលប៉ះពាល់បរិស្ថានដោយឯករាជ្យ ដើម្បីការពារ និង/ឬកាត់បន្ថយហានិភ័យនៃផលប៉ះពាល់អវិជ្ជមានកើតចេញពីដំណើរការអាជីវកម្មរបស់ពួកគេ មកលើការគោរពសិទ្ធិមនុស្ស[105]។

## 2. សិទ្ធិបុគ្គល ឬ ក្រុមជាក់លាក់

*ស្ត្រី*

